# ធម៌ឧទ្ទិសផល

ទានសីលខ្ញុំធ្វើហើយ ព្រះគុណណើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កុសលទាំងអស់នឹង សូមទីពឹងលើទេព្តា
សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
ទៅជូនឱ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯណេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ បន្ទន់កាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយកំសាន្ត សូមឱ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង ៕

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ອ៊ាន់ អ៊ុខ** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដោយនាងខ្ញុំ **ម៉ុក សារ៉ែន** ថ្ងៃទី១៨ ខែមីនា គ.ស.២០១២ * ពិនិត្យហើយនិងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន លី**

